# ស្ត្រីឆ្លងទន្លេ

ពេលព្រលប់យប់មួយនៅក្នុងឆ្នាំ ២០០១ សំលេងស្រែកយំដោយក្តីឈឺចាប់ និងស្រែកសុំអោយគេជួយបានលេចចេញពីទីងងឹតមួយនៅប៉ែកខាងកើតនៃវត្តភ្នំ។ សំលេងនោះគឺជាសំលេងស្ត្រីម្នាក់ដែលកំពុងសំរាលកូនដោយខ្លួនឯង ហើយដោយគ្មានអ្វីទាំងអស់នៅជុំវិញខ្លួននាង។ ដោយក្តីអាណិតអាសូរ និងអណោចអធម្មពេក អ្នកធាក់ស៊ីក្លូម្នាក់បានចុះ ហើយលើកនាងឡើងដាក់លើស៊ីក្លូ ហើយនាំនាងយកទៅមន្ទីរពេទ្យមួយនៅទីក្រុងភ្នំពេញ។ អ្នកធាក់ស៊ីក្លូម្នាក់បានបីនាងឡើងទៅរកបន្ទប់សំរាលកូន ហើយក៏ចេញបាត់ទៅបន្ទាប់ពីនិយាយពីរបីជាមួយមីងម្នាក់ដែលបានមកកំដរកូនស្រីគាត់នៅមន្ទីពេទ្យនោះដែរ។ ប្រហែលជា ២០ នាទីក្រោយមកអ្នកគ្រូពេទ្យម្នាក់បានចេញមកពីបន្ទប់សំរាលកូន ហើយសួររកសាច់ញាតិ។ មីងវណ្ណ "ឈ្មោះអ្នកនិពន្ធដាក់អោយ" នៅក្បែរនោះក៏ឆ្លើយប្រាប់អ្នកគ្រូពេទ្យនោះថា:

***"នាងគ្មានសាច់ញាតិទេ"***

អ្នកគ្រូពេទ្យម្នាក់នោះក៏សួរបន្តរថា:

***"ចុះអ្នកណានាំអ្នកជំងឺម្នាក់នោះមក"***

ដោយបាននិយាយជាមួយបុរសធាក់ស៊ីក្លូពីរបីមាត់មីងវណ្ណឆ្លើយ:

***"ខ្ញុំមិនដឹងដែរ ប៉ុន្តែពូ ម្នាក់ដែលបីនាងនោះឡើងមកប្រាប់ថា គាត់ជាអ្នកធាក់ស៊ីក្លូ ហើយគាត់ជិកនាងនោះមកពីម្តុំវត្តភ្នំ ដោយលឺសំលេងស្រែកអោយជួយ ហើយគាត់អាណិត គាត់ក៏ជិកមកទីនេះ"***

ដោយទឹកមុខមួរម៉ៅអ្នកគ្រូពេទ្យមិនសួរអ្វីទៀតហើយក៏ដើរចូលទៅបន្ទប់សំរាលវិញ ហើយទាញទ្វារបិទយ៉ាងខ្លាំង។ ប្រហែលជា ៥ នាទី សំលេងជេរបញ្ចោរក៏បានឡើងចេញពីបន្ទប់សំរាលនោះ ហើយគ្រូពេទ្យម្នាក់បានរុញនាងចេញពីបន្ទប់នោះ។ ដោយទឹកមុខស្លេកស្លាំងដោយគ្មានកំលាំង ហើយមានឈាមជាប់សំពត់នៅឡើយនោះ នាងមិនអាចទៅណារួចឡើយ នាងបានទំលាក់អង្គុយចុះក្បែរមាត់ទ្វារដែលនាងទើបតែត្រូវបានគ្រូពេទ្យម្នាក់រុញចេញ។ មិនឃើញនាងបីកូនរបស់នាងមកជាមួយនោះទេ ហើយនាងប្រហែលជាមិនដឹងថាកូននាងស្លាប់ រឺក៏រស់នោះដែរ។ គ្រប់គ្នានៅក្បែរនោះរួមទាំងមីងវណ្ណ គ្មានអ្នកណាម្នាក់ហ៊ានមាត់មួយមាត់ឡើយ។ ដោយក្តីអាណិតអាសូរមីងវណ្ណ បានយកបាយដែលកូនស្រីគាត់ហូប និងទឹកដោះគោឆៅមួយកំប៉ុងទៅអោយ។

មិនទាន់ទាំងច្រកបាយក្នុងមាត់ផង អ្នកគ្រូពេទ្យម្នាក់នោះបានចេញមកម្តងទៀត ហើយជេរនឹងបណ្តេញនាងចេញដោយប្រាប់ថា

***"អង្គុយកន្លែងនេះ ទើសផ្លូវដើរខ្លាំងណាស់ចេញអោយឆ្ងាយទៅ"***

ទោះបីជេរ រឺសំលាប់នាងក៏ដោយក៏នាងមិនអាចទៅណាបានឆ្ងាយឡើយ តែដោយទ្រាំនឹងសំដីមិនបាន នាងបានខំប្រឹងរំកិលខ្លួនចេញពីក្បែរមាត់ទ្វារនោះបានប្រហែល ១ ម៉ែត្រ។ ដោយគ្មានកំលាំងរំកិលខ្លួនបន្តរទៅទៀតបាន នាងក៏ទំលាក់ខ្លួនដេកនៅលើឥដ្ឋក្បែរជញ្ជាំងនោះដោយលែងអើរពើរនឹងការជេរប្រមាទពីអ្នកគ្រូពេទ្យម្នាក់នោះ។ ដោយឃើញអ្នកគ្រូពេទ្យម្នាក់នោះទៅបាត់ មីងវណ្ណ និងអ្នកដ៏ទៃទៀតទៅមើលនាង និងនាំគ្នាអង្រួននាងដោយគិតថានាងសន្លប់ រឺស្លាប់។ នាងបានបើកភ្នែកហើយខំប្រឹងងើបអង្គុយ ហើយអ្នកក្បែរនោះបានជួយទប់នាងអោយអង្គុយ។ ភ្លាមនោះមីងវណ្ណ បានគាស់ទឹកដោះគោឆៅអោយនាង ហើយសួរថា "នាងមកពីណា ហើយមានបងប្អូនរឺអត់?" នាងមិនបានឆ្លើយតែនាងបានសុំទឹកដោះគោនោះផឹក។ មិនទាន់ទាំងផឹកទឹកដោះគោនោះអស់ផងសំលេងជេរបញ្ចោបានលឺម្តងទៀត ម្តងនេះមិនមែនជាអ្នកគ្រូពេទ្យម្នាក់នោះទៀតទេ តែជាអ្នកបោសជូតអោយមន្ទីរពេទ្យនោះ។ អ្នកបោសជូតនោះជេរដោយសារតែឃើញស្នាមឈាមដែលប្រឡាក់នៅលើឥដ្ឋ ជាឈាមដែលស្រក់ចេញពីសំពត់នាងនៅពេលដែលអ្នកធាក់ស៊ីក្លូបីនាងឡើងមក។ គ្រប់គ្នាបានដើរចេញ ហើយគ្មាននរណាម្នាក់មាត់មួយមាត់ឡើយ។ ម្តងនេះគេឃើញនាងអាចងើបរួចហើយហើយខំប្រឹងដើរដោយតោងបង្កាន់ដៃដើម្បីចាកចេញពីមន្ទីរពេទ្យនោះដោយមិននិយាយអ្វីមួយមាត់ឡើយ។ ដោយមិនអស់ចិត្តមីងវណ្ណបានសួរនាងនោះថា

***"នាងទៅណា?"***

នាងបានបែរមករកមីងវណ្ណហើយឆ្លើយដោយសំលេងខ្សាវៗថា:

***"អគុណមីង ខ្ញុំទៅហើយ"***

ចុងបញ្ចប់នៃការនិទានប្រាប់អ្នកនិពន្ធមីងវណ្ណបានប្រាប់អ្នកនិពន្ធថា:

***"តាំងពីពេលនោះមកមនុស្សដែលខ្ញុំខ្លាចជាងគេគឺពេទ្យ ខ្ញុំនឹងមិនទៅមន្ទីរពេទ្យទៀតទេ បើខ្ញុំគ្មានលុយ ខ្ញុំខ្លាចរឿងនេះកើតមកលើកូនចៅខ្ញុំខ្លាំងណាស់"***

រឿងនេះអ្នកនិពន្ធបានទទួលនៅដើមឆ្នាំ ២០០៨ កំឡុងពេលដែលគាត់ធ្វើការអោយអង្គការក្រៅរដ្ឋាភិបាលមួយនៅខេត្តកណ្តាល។